

# វត្តគិរីវង្សាបុប្ផារាម

## WAT KIRY VONGSA BOPHARAM

**អាស្រមសមាធិសន្តិភាព** The Peace Meditation Center

100A Cave Hill Road, Leverett, MA 01054 - 9728 U.S.A.

TEL.: 413.367.0280; E-mail: vipassanadhura@gmail.com



# ពិធីបុណ្យផ្កាប្រាក់

## ២៥ កក្កដា ព.ស.២៥៦៥ គ.ស.២០២១

ព្រះចៅអធិការ សមាជិកគណៈកម្មការ ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្តបានផ្តួចផ្តើមប្រារព្ធពិធីបុណ្យផ្កាប្រាក់នេះឡើង ដើម្បីជួយឧបត្ថម្ភបង់ថ្លៃអគ្គិសនី ប្រេងសម្រាប់កំដៅវត្ត និងការកសាងផ្សេងៗ នៅក្នុងវត្ត ពីព្រោះសព្វថ្ងៃនេះ វត្តមានការខ្វះខាត ដោយសារជំងឺរាតត្បាតខូវីត-១៩។

អាស្រ័យហេតុនេះ អាត្មាភាព យើងខ្ញុំជាសមាជិកគណៈកម្មការ សូមអំពាវនាវដល់សន្តានចិត្តសប្បុរសជនទាំងឡាយអញ្ជើញចូលរួមផ្តើមធ្វើបុណ្យផ្កាប្រាក់ ដើម្បីយកមកវេរប្រគេនដល់ព្រះសង្ឃសម្រាប់កសាងវត្ត ហើយសូមត្រេកអរអនុមោទនាបុណ្យកុសលក្នុងពិធីបុណ្យនេះគ្រប់គ្នា។

## កម្មវិធីបុណ្យ

***ថ្ងៃសៅរ៍ ១៥កើត ថ្ងៃសីល ខែទុតិយាសាឍ ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា គ.ស.២០២១**

ម៉ោង ៦:៣០នាទីល្ងាច — នមស្ការ សមាទានសីល ចម្រើនព្រះបរិត្ត សម្តែងធម៌ទេសនា

***ថ្ងៃអាទិត្យ ១រោច ខែទុតិយាសាឍ ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា គ.ស.២០២១**

សូមរម្លឹកថា ថ្ងៃអាទិត្យដដែលនេះ ត្រូវជាថ្ងៃចូលព្រះវស្សាផងដែរ។

| | |
|---|---|
| វេលាម៉ោង ៧:០០នាទីព្រឹក | ប្រគេនយាគូព្រះសង្ឃ |
| វេលាម៉ោង ៩:០០នាទីព្រឹក | ជួបជុំអង្គផ្កា |
| វេលាម៉ោង ៩:៣០នាទីព្រឹក | រាប់បាត្រ |
| វេលាម៉ោង ១០:០០នាទីព្រឹក | នមស្ការ សមាទានសីល វេរភត្តប្រគេនព្រះសង្ឃ និមន្តព្រះសង្ឃធ្វើដារបង្សុកូល ឧទ្ទិសកុសលជូនវិញ្ញាណដូនតា ញាតិកាក្នុងវាលវដ្តសង្សារ |
| វេលាម៉ោង ១២:០០ថ្ងៃត្រង់ | ទទួលទានអាហារថ្ងៃត្រង់ |
| វេលាម៉ោង ១:០០នាទីរសៀល | ដង្ហែអង្គផ្កាប្រទក្សិណបីជុំវិហារ វេរប្រគេនព្រះសង្ឃជាកិច្ចបញ្ចប់បុណ្យផ្កាប្រាក់៕ |

សូមសព្វសត្វលោកប្រកបតែសេចក្តីសុខ និងបានរួចផុតពីទុក្ខវេទនា។